អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណៅជាលាយលក្ខណ៍អក្សរនៃសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ ដែលថ្លែងដោយលោក
# Robert Petit
# សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសន្និសីទសារព័ត៌មានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩

ខ្ញុំចង់បញ្ជាក់ជូនលោក-លោកស្រីនៅថ្ងៃនេះ ដោយយោងទៅលើព្រឹត្តិការណ៍នាពេលកន្លងទៅ ខ្ញុំបានប្រមើលឃើញថា សេចក្តីប្រកាសព័ត៌មានរបស់ខ្ញុំកាលពីម្សិលមិញ ពុំគ្រប់គ្រាន់ដើម្បីគ្របដណ្តប់ឲ្យបានពេញលេញទៅលើប្រធានបទនេះទេ។ ខ្ញុំថែមទាំងជឿជាក់ថា វាជាប្រធានបទមួយមិនពាក់ព័ន្ធនឹងតុលាការនេះទេ។

ហេតុដូច្នេះ ខ្ញុំនឹងព្យាយាមគ្របដណ្តប់ទៅលើអ្វីដែលខ្ញុំគិតថា ជាប់ពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីអាចមានការយកចិត្តទុកដាក់លើបញ្ហាខ្លឹមសាររបស់តុលាការនេះវិញ។

<u>ទីមួយ មូលហេតុរបស់ខ្ញុំសម្រាប់ការចាកចេញ៖</u>

មូលហេតុទាំងនេះទាក់ទងទាំងស្រុងទៅនឹងបញ្ហាផ្ទាល់ខ្លួននៅក្នុងគ្រួសារ គឺវាមិនពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើវិជ្ជាជីវៈរបស់ខ្ញុំនៅតុលាការនេះទេ ហើយហេតុដូច្នេះ ជាបញ្ហាឯកជនទាំងស្រុង។ ខ្ញុំជឿជាក់យ៉ាងមុតមាំចំពោះសិទ្ធិទទួលបានភាពឯកជន ហើយខ្ញុំរំពឹងថា សិទ្ធិនេះនឹងត្រូវបានគោរព។

នៅក្នុងពិភពជាក់ស្តែងនេះ មនុស្សយើងមានអាទិភាពផ្សេងៗគ្នា ដែលពេលខ្លះវាទំនាស់គ្នាថែមទៀតផង ហើយត្រូវដោះស្រាយឲ្យស្របតាមគោលការណ៍អ្វីមួយ ដែលមនុស្សម្នាក់ប្រកាន់យក។

តាមបទពិសោធរបស់ខ្ញុំ កាលណាបញ្ហាកាន់តែសំខាន់ នោះគោលការណ៍ក៏កាន់តែសំខាន់ដែរ ហើយសេចក្តីសម្រេចក៏រឹតតែតឹងតែងដែរ។ នេះជាករណីមួយ ក្នុងចំណោមករណីទាំងនោះ។

នេះជាការសម្រេចចិត្តដ៏ពិបាកបំផុតនៅក្នុងវិជ្ជាជីវៈរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំជឿជាក់ថា វាជាការសម្រេចចិត្តត្រឹមត្រូវមួយ។

វាក៏ជាការសម្រេចចិត្តដែលត្រូវបានធ្វើឡើង បន្ទាប់ពីការឆ្លុះបញ្ចាំង និងការពិភាក្សាអស់រយៈពេលជាច្រើនខែជាមួយអង្គការសហប្រជាជាតិ ដែលកំពុងស្ថិតនៅក្នុងដំណើរការនៃការស្វែងរកអ្នកមកជំនួស។ ខ្ញុំមានជំនឿទុកចិត្តថា អង្គការសហប្រជាជាតិនឹងដោះស្រាយឆាប់ៗនេះ ហើយបញ្ហាណាមួយទាក់ទងនឹងដំណើរការនេះ គួរត្រូវបានបញ្ជាក់ជូនអនុប្រធានការិយាល័យរដ្ឋបាល។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ឃើញថា ការលើកឡើងនេះអាចធ្វើឱ្យអ្នកខ្លះមិនពេញចិត្ត ហើយខ្ញុំសូមអភ័យទោសចំពោះការមិនពេញចិត្តនេះ។ ប៉ុន្តែ ខ្ញុំពុំជឿជាក់ថា វាសមស្របក្នុងការផ្សព្វផ្សាយពីជីវិតឯកជនរបស់អ្នកណាម្នាក់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយនោះឡើយ។

ប៉ុន្តែ ខ្ញុំក៏យល់ផងដែរថា អ្នកខ្លះនឹងនៅតែខិតខំព្យាយាមបកស្រាយពីចំណុចខ្លះដែលមិនពាក់ព័ន្ធទៅនឹងការសម្រេចចិត្តនេះ ទោះក្នុងគោលបំណងអ្វីក៏ដោយ។

មានចំណុចតិចតួចណាស់ដែលគេអាចបកស្រាយជំទាស់ទៅនឹងប្រភេទនៃវិធីសាស្ត្រនោះ ហើយជាការពិតការរួមគំនិតទាំងនោះវាគ្រាន់តែជាទិដ្ឋភាពមួយគួរឱ្យទាក់ទាញ សម្រាប់ដំណើររឿងមួយប៉ុណ្ណោះ។ ប៉ុន្តែ វាមិនមែនជាការពិតនោះឡើយ។

ខ្ញុំគ្រាន់តែសូមនិយាយឡើងវិញជាចុងក្រោយថា ការសម្រេចចិត្តរបស់ខ្ញុំនេះពុំមានអ្វីជាប់ពាក់ព័ន្ធជាមួយតុលាការនេះ ជាមួយកិច្ចការសព្វថ្ងៃរបស់ខ្ញុំ ឬជាមួយប្រទេសកម្ពុជានោះទេ។ ផ្ទុយទៅវិញ ការសម្រេចចិត្តនេះពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើងក្នុងប្រទេសកាណាដាឯណោះទៅវិញទេ។

<u>ទីពីរ ផលប៉ះពាល់ដែលអាចនឹងកើតមានទៅលើកិច្ចការរបស់តុលាការនេះ ចំពោះការជំនួសមុខតំណែងរបស់ខ្ញុំ៖</u>

ទោះបីជាការនិយាយបែបនេះធ្វើឲ្យប៉ះពាល់តម្លៃផ្ទាល់ខ្លួនរបស់ខ្ញុំខ្លាំងប៉ុណ្ណាក្ដី ក៏ខ្ញុំមិនជឿថា វានឹងធ្វើឲ្យប៉ះពាល់នោះឡើយ។

ប៉ុន្តែខ្ញុំអាចយល់បាន ថាតើអ្នកដែលមិនធ្លាប់ដឹងអំពីដំណើរការនេះ អាចគិតផ្សេងពីនេះដោយរបៀបណានោះ។ ដូច្នេះ អនុញ្ញាតឲ្យខ្ញុំពន្យល់អំពីបញ្ហានេះបន្តិច។

សូមមើលទៅលើរឿងក្ដី ឌុច។ ចំពោះរឿងក្ដីទាំងអស់របស់យើង រឿងក្ដីនេះត្រូវបានច្របាច់បញ្ចូលគ្នាតាំងពីដើមដំបូងមក ដោយមនុស្សមួយក្រុមធ្វើការរួមគ្នា ដោយមានមនុស្សម្នាក់មកពីផ្នែកម្ខាងនៃការិយាល័យដែលទទួលបន្ទុកលើរឿងក្ដីនេះ។

ភស្តុតាងត្រូវបានប្រមូល និងវិភាគ សេចក្ដីសម្រេចតាមផ្លូវច្បាប់ និងជាយុទ្ធសាស្ត្រ ត្រូវបានចេញ ហើយចំណុចទាំងអស់នេះបានកើតឡើងសម្រាប់ខាងយើងខ្ញុំ ដោយមានការពិគ្រោះយោបល់រវាងខ្ញុំជាមួយនឹងអនុរបស់ខ្ញុំ ហើយនេះជារបៀបដែលខ្ញុំចាត់ចែងការងារនៅក្នុងការិយាល័យរបស់ខ្ញុំ។

នៅពេលដែលដឹងច្បាស់ថា អ្នកច្បាប់ជាន់ខ្ពស់នៅក្នុងរឿងក្ដីនេះនឹងត្រូវចាកចេញ អនុរបស់ខ្ញុំក៏បានចាប់ផ្ដើមរៀបចំខ្លួន ហើយឥឡូវនេះគាត់កំពុងតែដឹកនាំរឿងក្ដី ហើយគាត់នឹងបំពេញកិច្ចការបែបនេះរហូតទាល់តែមានការជូនដំណឹងបន្ថែម។

តើការផ្លាស់ប្ដូរបុគ្គលិកបែបនេះ បានកែប្រែភស្តុតាងនៅក្នុងសំណុំរឿងខ្លះដែរឬទេ? តើវាបានជះឥទ្ធិពលណាមួយទៅលើរបៀបដែលយើងបានសម្រេចដើម្បីបង្ហាញរឿងក្ដី និងជួយដល់អង្គជំនុំជម្រះសាលាដំបូងដែរឬទេ? ពិតហើយ គឺអត់នោះទេ។

សំអាងហេតុដូចគ្នានេះអនុវត្តចំពោះសំណុំរឿងទីពីរ។ ការិយាល័យនេះទាំងមូល ដែលបានដាក់រឿងក្ដីនេះបញ្ចូលគ្នា បាននឹងកំពុងតែតាមឃ្លាំមើលទៅលើកិច្ចស៊ើបសួរ និងកំពុងតែឆ្លើយតបទៅនឹងការអភិវឌ្ឍទាំងឡាយ។ នៅពេលឈានដល់ការជំនុំជម្រះ យើងដែលតំណាងឲ្យការិយាល័យមួយ ទោះបីតាមរយៈអ្នកណាជាអ្នកឡើងនិយាយនៅក្នុងតុលាការនេះក៏ដោយ គឺនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងមិនខាន។

នេះជារបៀបសាមញ្ញមួយ ថាតើរឿងក្ដីទាំងនេះត្រូវយកមកចោទប្រកាន់ដោយរបៀបណា ចំពោះការខិតខំប្រឹងប្រែងជាក្រុម ពីព្រោះថា គ្នាច្រើនប្រសើរជាងមនុស្សតែមួយនាក់ នៅគ្រប់ចំណុចទាំងអស់។

មានការសន្មតខ្លះៗផងដែរថា ការលាលែងនេះអាចប៉ះពាល់ទៅលើការខ្វែងយោបល់គ្នាដែលកំពុងតែកើតមានឡើងជាមួយនឹងសហព្រះរាជអាជ្ញាជាតិរបស់ខ្ញុំ។ ប៉ុន្តែជាថ្មីម្ដងទៀត ការព្រួយបារម្ភទាំងនេះពុំមានមូលដ្ឋាននោះឡើយ។ នៅក្នុងខែធ្នូ ឆ្នាំមុននេះ ខ្ញុំបានធ្វើសេចក្ដីសម្រេចចិត្តដោយយោងទៅលើភស្តុតាង ច្បាប់ និងអាណត្តិការងាររបខ្ញុំ។ ខ្ញុំបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវភស្តុតាង និងទឡ្ហីករណ៍ទាំងនេះ ក៏ដូចជាសំណើនានាដែលបានចុះហត្ថលេខាផងដែរ ដែលខ្ញុំបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ។ សហការីជាតិរបស់ខ្ញុំក៏បានធ្វើដូចគ្នានេះដែរ ហើយពេលនេះ សំណុំរឿងនេះត្រូវបានស៊ើបអង្កេតបន្ថែម ដូចបានស្នើឡើងដោយអង្គជំនុំជម្រះដែលបាននិយាយថា ខ្លួនមានព័ត៌មានគ្រប់គ្រាន់នៅក្នុងសំណុំរឿង ដើម្បីចេញសេចក្ដីសម្រេចបានហើយ។ នៅពេលទទួលបានព័ត៌មានដូច្នេះ ខ្ញុំ ឬអ្នកស្នងតំណែងរបស់ខ្ញុំនឹងចាត់ការឲ្យបានសមស្របចាប់ពីពេលនោះមក។ សេចក្ដីសម្រេចចិត្តរបស់ខ្ញុំមិនអាចមានផលប៉ះពាល់ណាមួយទៅលើរឿងក្ដីនេះទៅលើស្ថានភាពនៃការខ្វែងយោបល់គ្នា ឬទៅលើសេចក្ដីសម្រេចចិត្តណាមួយនោះទេ។ រឿងក្ដីនេះស្ថិតនៅក្នុងដៃរបស់ អ.ប.ជ ទាំងស្រុង។ ហើយតាមដែលខ្ញុំដឹង បញ្ហាប្រឈមទាំងនោះនឹងមិនទៅណាឆ្ងាយទេ។

តុលាការមិនអចិន្ត្រៃយ៍ទាំងអស់ តុលាការកូនកាត់ទាំងអស់មានការផ្លាស់ប្ដូរជាច្រើនទៅលើរដ្ឋអាជ្ញា ប្រធានតុលាការ ក្រឡាបញ្ជី និងបុគ្គលិកសំខាន់ៗ ក្រៅពីចៅក្រមជំនុំជម្រះនៅក្នុងរឿងក្ដីដែលកំពុងតែបន្តដំណើរការ ហើយអាចនិយាយដោយស្មោះបានថា ការផ្លាស់ប្ដូរទាំងអស់នោះពុំមានផលប៉ះពាល់សំខាន់ណាមួយទៅលើដំណើរការរបស់តុលាការទាំងនោះទេ។

នៅក្នុងតុលាការទំនើបដែលវិនិច្ឆ័យលើឧក្រិដ្ឋកម្មសង្គ្រាម ព័ត៌មានពាក់ព័ន្ធទាំងអស់ត្រូវបានយកមកពិចារណាយ៉ាងច្បាស់លាស់ចំពោះសំណុំរឿងនេះ ទាំងព័ត៌មានជាអេឡិកត្រូនិច និងជាឯកសាររឹង ដើម្បីចៀសវាងកុំឲ្យផលប៉ះពាល់ទៅលើការផ្លាស់ប្ដូរបុគ្គលិកធ្វើការលើរឿងក្ដីទាំងនោះ។

អ្វីដែលជាបញ្ហាចោទនោះគឺថា មានមនុស្សម្នាក់កាន់មុខតំណែងមួយ ដែលត្រូវបានផ្ដល់សិទ្ធិអំណាចតាមផ្លូវច្បាប់ដើម្បីធ្វើការសម្រេចចិត្តនានា និងគ្រាន់តែបំពេញកិច្ចបែបនោះឯង។ ដំណើរការក្រៅពីនោះ គឺប្រព្រឹត្តទៅជាធម្មតារបស់វា។

ចុងក្រោយបង្អស់ ខ្ញុំចង់និយាយឡើងវិញថា ខ្ញុំចាត់ទុកថាវាជាមហាបុព្វសិទ្ធិបំផុត ដែលខ្ញុំមានលទ្ធភាពធ្វើការជាមួយក្រុមមនុស្សដែលមានការប្តេជ្ញាចិត្តលេចធ្លោទាំងខាងភាគីជាតិ និងអន្តរជាតិ នៅក្នុងការព្យាយាមនាំខ្លួនអ្នកទទួលខុសត្រូវខ្លះមកផ្តន្ទាទោស និងនាំយកយុត្តិធម៌ខ្លះជូនជនរងគ្រោះដោយរបបខ្មែរក្រហម។

ទោះបីជាវាពិតហើយថា បេសកកម្មនេះមិនមែនជាការងាយស្រួលក៏ដោយ ហើយតុលាការនេះមានការប្រឈមជាច្រើន ហើយប្រហែលជានឹងត្រូវបន្តប្រឈមទៅនឹងបញ្ហាធ្ងន់ធ្ងរទាំងឡាយ រហូតដល់ចុងបញ្ចប់ក្តី ក៏ការប្រឈមទាំងនេះមិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចចិត្តរបស់ខ្ញុំទេ ប៉ុន្តែវាជាការជម្រុញទឹកចិត្តយ៉ាងខ្លាំងដើម្បីបន្តជំនះនឹងការប្រឈមទាំងនេះ។

សម្រាប់រយៈពេលម្ភៃឆ្នាំ ទាំងនៅក្នុងប្រទេសកាណាដា និងនៅបរទេស ខ្ញុំបានជឿជាក់ក្នុងការព្យាយាមលើកស្ទួយដល់នីតិរដ្ឋ ដែលជាការធានាដ៏ប្រសើរបំផុតឲ្យមានសន្តិភាព សន្តិសុខ និងយុត្តិធម៌។ ខ្ញុំនៅតែជឿជាក់ថា តុលាការនេះអាចជួយឲ្យប្រទេសកម្ពុជាសម្រេចបាននូវគោលដៅទាំងនោះ។

សូមអរគុណ